# ព្រះរាជក្រម

នស/រកម/១២១៧/០១៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨



## ជំពូកទី១
## ថវិកាថ្នាក់ជាតិ

**មាត្រា១ ._**

ត្រូវបានអនុញ្ញាតសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ឱ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិនូវពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឱ្យសម្រេចនូវឧបត្ថម្ភធនវិនិយោគនិងការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "**ក១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន២២ ៤៣៧ ១៣៨លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលចរន្ត...................................................... ១៧ ៤៦០ ០០៦លានរៀល
- ចំណូលមូលធន....................................................៤ ៩៧៧ ១៣២លានរៀល

  \+ ចំណូលមូលធនក្នុងប្រទេស...............................១៨០ ១៩៣លានរៀល

  \+ ចំណូលមូលធនក្រៅប្រទេស...........................៤ ៧៩៦ ៩៣៩លានរៀល

  - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ............................................................២៥០ ០០០លានរៀល
  - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស .......................................................៤ ៥៤៦ ៩៣៩លានរៀល។

**មាត្រា២ ._**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបានកំណត់ស្មើនឹង២៣ ៤២៨ ២៩៨លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត...................................................... ១៥ ២១៨ ១៦៦លានរៀល
- ចំណាយមូលធន....................................................៨ ២១០ ១៣២លានរៀល

ក- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

..................................................................... ២ ៩២៥ ៨០០លានរៀល

- ដោយថវិកាថ្នាក់ជាតិ...............................២ ៦៧៥ ៨០០លានរៀល
  - គម្រោងវិនិយោគផ្ទាល់...............២ ០៧៥ ៨០០លានរៀល

▪ បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស ............................................. ៦០០ ០០០លានរៀល

- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ........................................................ ២៥០ ០០០លានរៀល

ខ- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ................................................................ ៤ ៥៤៦ ៩៣៩លានរៀល

គ- ការទូទាត់ការខ្ចី........................................ ៧៣៧ ៣៩៣លានរៀល។

**មាត្រា៣ .-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបានកំណត់ស្មើនឹង១៥ ២១៨ ១៦៦លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "**ខ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៤ .-**

ចំនួនទឹកប្រាក់នៃឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស សម្រាប់ការគ្រប់គ្រងពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ ត្រូវបានកំណត់ស្មើនឹង២១ ៣៤១ ៥៩៨លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗតាមគម្រោងនិងតាមឆ្នាំ ដូចមានចែងក្នុងតារាង "**គ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៥ .-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយមូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបានកំណត់ដូចខាងក្រោម ៖

- ឥណទានភ្ជាប់សន្យា............................... ៨ ២១០ ១៣២លានរៀល
- ឥណទានទូទាត់.................................. ៨ ២១០ ១៣២លានរៀល។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ឥណទាននេះត្រូវបានបែងចែកដូចតទៅ ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា................................២ ៩២៥ ៨០០លានរៀល
- ឥណទានទូទាត់......................................២ ៩២៥ ៨០០លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា............................... ៤ ៥៤៦ ៩៣៩លានរៀល
- ឥណទានទូទាត់..................................... ៤ ៥៤៦ ៩៣៩លានរៀល

គ. ការទូទាត់ការខ្ចី

- ឥណទានភ្ជាប់សន្យា..................................៧៣៧ ៣៩៣លានរៀល
- ឥណទានទូទាត់......................................៧៣៧ ៣៩៣លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗដូចមានចែងក្នុងតារាង "**គ២**" និង "**ឃ**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៦ .-**

តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលបានរៀបចំនៅក្នុងតារាង "**ក១**" ស្តីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "**ខ១**" ស្តីពីចំណាយថវិកាថ្នាក់ជាតិត្រូវបានបង្ហាញនៅក្នុងតារាងកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិដូចខាងក្រោម ៖

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ | ចំនួនទឹកប្រាក់ | តុល្យភាព/ ហិរញ្ញប្បទាន |
|---|---|---|
| I. ចំណូលក្នុងប្រទេសសរុប | ១៧ ៦៤០ ១៩៩ | |
| ១. ចំណូលចរន្ត | ១៧ ៤៦០ ០០៦ | |
| ២. ចំណូលមូលធនក្នុងប្រទេស | ១៨០ ១៩៣ | |
| II. ចំណាយថវិកាសរុប | ២២ ៦៩០ ៩០៥ | |
| ១. ចំណាយចរន្ត | ១៥ ២១៨ ១៦៦ | |
| ២. ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី) | ៧ ៤៧២ ៧៣៩ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ២ ៩២៥ ៨០០ | |
| + ដោយថវិកាថ្នាក់ជាតិ | ២ ៦៧៥ ៨០០ | |
| - គម្រោងវិនិយោគផ្ទាល់ | ២ ០៧៥ ៨០០ | |
| - បដិភាគវិនិយោគ | ៦០០ ០០០ | |
| + ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍ | ២៥០ ០០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៤ ៥៤៦ ៩៣៩ | |
| អតិរេកនៃថវិកាចរន្ត ( I.១ -II.១ ) | | +២ ២៤១ ៨៤០ |
| ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ (I-II) | | -៥ ០៥០ ៧០៦ |
| III. ហិរញ្ញប្បទាននៃឱនភាព | | +៥ ០៥០ ៧០៦ |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | +៤ ០៥៩ ៥៤៦ |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | +២៥០ ០០០ |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | +៤ ៥៤៦ ៩៣៩ |
| • ការទូទាត់ការខ្ចី | | - ៧៣៧ ៣៩៣ |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | +៩៩១ ១៦០ |
| • បញ្ញើរាជរដ្ឋាភិបាល | | +៩៩១ ១៦០ |

# ជំពូកទី២
## ការខ្ចីនិងការធានារបស់រដ្ឋ

**មាត្រា៧ .-**

សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេក្នុងកម្រិត១ ០០០ ០០០ ០០០ SDR(មួយប៊ីលានអេសដេអ៊ែរ)។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកម្រិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ។

នៅក្នុងលក្ខខណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងការចុះហត្ថលេខាលើការខ្ចី ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬលើការធានារបស់រដ្ឋ ហើយត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តនៃការខ្ចីនិងការធានានេះ ជូនរដ្ឋសភានិងព្រឹទ្ធសភារៀងរាល់ ៦ខែម្តង។

**មាត្រា៨ .-**

មិនអនុញ្ញាតឱ្យក្រសួង ឬស្ថាប័នសាធារណៈណាមួយចំណុះរដ្ឋ មានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្ររយៈពេលវែង មធ្យម ខ្លី ឬឥណទានអ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬការធានាកិច្ចសន្យា ដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬតាមឆ្នាំ ដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុនិងលក្ខខណ្ឌទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី៣

## បទប្បញ្ញត្តិស្តីពីពន្ធដារ

**មាត្រា៩ .-**

ច្បាប់ស្តីពីការបង្កើតពន្ធសត្តឃាត ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ១៧ ក្រ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

មាត្រា៤៧ថ្មី(មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលត្រូវបានកែសម្រួលដោយ មាត្រា១០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ត្រូវបានកែប្រែ ដូចខាងក្រោម ៖

មាត្រា៤៧ .-ថ្មី (ពីរ)

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធ ប្រចាំខែ និងត្រូវកាត់ទុកដោយនិយោជកតាមអត្រាកំណើនតាមថ្នាក់ ដូចតទៅ ៖

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ១ ២០០ ០០០៛ | ០% |
| ពី | ១ ២០០ ០០១៛ | ដល់ | ២ ០០០ ០០០៛ | ៥% |
| ពី | ២ ០០០ ០០១៛ | ដល់ | ៨ ៥០០ ០០០៛ | ១០% |
| ពី | ៨ ៥០០ ០០១៛ | ដល់ | ១២ ៥០០ ០០០៛ | ១៥% |
| | | លើសពី | ១២ ៥០០ ០០០៛ | ២០% |

**មាត្រា១១ .-**

ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងវិសោធនកម្មជាបន្តបន្ទាប់ ត្រូវបានធ្វើវិសោធនកម្មបំពេញ និងបន្ថែម ដូចខាងក្រោម ៖



១- ជំពូកទី៦ នៃច្បាប់ស្តីពីសារពើពន្ធ ស្តីពីអវសានប្បញ្ញត្តិ ត្រូវបានប្តូរជា ជំពូកទី៧ ដែលក្នុងនោះមាត្រា១៤១ ត្រូវបានប្តូរជា មាត្រា១៥៤ និងមាត្រា១៤២ ត្រូវបានប្តូរជា មាត្រា១៥៥។

២- ត្រូវបានជំនួស ជំពូកទី៦ បទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ ដែលចែកចេញជា ៦ ផ្នែក មានចំនួន ១៣ មាត្រា ចាប់ពីមាត្រា១៤១ ដល់មាត្រា១៥៣ ដូចតទៅ ៖

**<< ជំពូកទី ៦**

**បទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ**

**ផ្នែកទី១**

**បទប្បញ្ញត្តិទូទៅ**

មាត្រា១៤១ .-

បទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែនេះ អនុវត្តចំពោះប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ នៅក្នុងបូរណភាពទឹកដីនិងអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងបាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្រនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខនិងតំបន់ខ្ពង់រាបបាតសមុទ្រ ព្រមទាំងតំបន់ផ្សេងៗទៀតដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអធិបតេយ្យ។

មាត្រា១៤២ .-

វាក្យសព្ទនិងនិយមន័យសំខាន់ៗសម្រាប់ប្រើប្រាស់ក្នុងជំពូកនេះ មានដូចខាងក្រោម ៖

១- សម្រាប់គោលដៅនៃប្រតិបត្តិការប្រេងកាត ៖

ក. ពាក្យ "ប្រេងកាត" សំដៅដល់ប្រេងឆៅ ឧស្ម័នធម្មជាតិ ឬអ៊ីដ្រូកាបួរផ្សេងទៀត ទោះជាស្ថិតក្នុងសភាពរឹង រាវ ឧស្ម័ន ក្នុងស្ថានភាពធម្មជាតិ និងរាល់សារធាតុផ្សេងទៀតដែលជាសមាសធាតុផ្សំជាមួយអ៊ីដ្រូកាបួរនោះ

ខ. ពាក្យ "កិច្ចព្រមព្រៀងប្រេងកាត" សំដៅដល់កិច្ចព្រមព្រៀង ឬការអនុញ្ញាតដែលត្រូវបានផ្តល់ឱ្យក្រោមច្បាប់និងបទប្បញ្ញត្តិស្តីពីប្រេងកាត រវាងរាជរដ្ឋាភិបាលកម្ពុជា និងអ្នកជាប់ពន្ធពាក់ព័ន្ធដើម្បីធ្វើប្រតិបត្តិការប្រេងកាត

គ. ពាក្យ "ប្រតិបត្តិការប្រេងកាត" សំដៅដល់សកម្មភាពស្វែងរុករក អភិវឌ្ឍ និងផលិតប្រេងកាត ដែលបានធ្វើឡើងនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងប្រេងកាត ស្របតាមកិច្ចព្រមព្រៀងប្រេងកាត

ឃ. ពាក្យ "តំបន់ចុះកិច្ចសន្យា" សំដៅដល់តំបន់ដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ប្រេងកាត ដែលបានអនុញ្ញាតផ្តល់ឱ្យពីដំបូង រួមបញ្ចូលទាំងផ្នែកណាមួយនៃតំបន់នោះដែលត្រូវបានបោះបង់ចោល ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងប្រេងកាត

ង. ពាក្យ "គម្រោងអភិវឌ្ឍន៍" សំដៅដល់កម្មវិធីការងារអភិវឌ្ឍន៍ ដើម្បីអភិវឌ្ឍ និងធ្វើផលិតកម្មធនធានប្រេងកាតនៅក្នុងតំបន់ចុះកិច្ចសន្យា ដែលបានយល់ព្រមដោយស្ថាប័ន

ច. ពាក្យ "គម្រោងរុះរើបោសសម្អាត" សំដៅដល់គម្រោងរុះរើបោសសម្អាតរបស់អ្នកជាប់ពន្ធដែលបានយល់ព្រមដោយស្ថាប័នក្រោមកិច្ចព្រមព្រៀងប្រេងកាត

ឆ. ពាក្យ "ចំណាយបុរេសនា" សំដៅដល់ចំណាយក្នុងការស្វែងរុករកដើម្បីកំណត់សក្តានុពលភូគព្ភសាស្ត្រប្រេងកាតដំហានដំបូង ដោយមិនមានសិទ្ធិធ្វើការអភិវឌ្ឍនិងផលិតកម្ម

ជ. ពាក្យ "ចំណាយស្វែងរុករក" សំដៅដល់ចំណាយក្នុងការអង្កេតផ្នែកភូគព្ភសាស្ត្រ រូបភូគព្ភសាស្ត្រ គីមីភូគព្ភសាស្ត្រ ចំណាយវិភាគទិន្នន័យ ចំណាយទស្សនទានវិស្វកម្មមុនពេលអភិវឌ្ឍន៍ ចំណាយលើការខួងស្វែងរុករក ខួងវាយតម្លៃ ការសិក្សាលើសមិទ្ធិលទ្ធភាព ផលប៉ះពាល់បរិស្ថាន ចំណាយរដ្ឋបាលទូទៅ និងចំណាយផ្សេងៗទៀតដែលកើតឡើងនៅក្នុងការស្វែងរុករក

ឈ. ពាក្យ "ចំណាយអភិវឌ្ឍន៍" សំដៅដល់ចំណាយដែលបានកើតឡើងបន្ទាប់ពីស្ថាប័នបានយល់ព្រមចំពោះគម្រោងអភិវឌ្ឍន៍ ដើម្បីសាងសង់មធ្យោបាយផលិតកម្មសម្រាប់ប្រតិបត្តិការប្រេងកាត ជាអាទិ៍មាន ការរៀបចំទីតាំង ការខួងអណ្តូង ការសាងសង់អណ្តូងសម្រាប់ផលិតកម្ម និងការសាងសង់បំពង់បង្ហូរប្រេងកាតដែលជាមធ្យោបាយផលិតកម្ម ព្រមទាំងចំណាយផ្សេងៗទៀតដែលកើតឡើងនៅក្នុងការអភិវឌ្ឍស្របតាមកិច្ចព្រមព្រៀងប្រេងកាត

ញ. ពាក្យ "ប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត" សំដៅដល់ប្រាក់បម្រុងដែលត្រូវបានអនុញ្ញាតឱ្យកាត់កងជាមុន សម្រាប់ចំណាយរុះរើបោសសម្អាតដែលនឹងកើតឡើងស្របតាមគម្រោងរុះរើបោសសម្អាត

ដ. ពាក្យ "ចំណាយសរុបដែលបានយល់ព្រមសម្រាប់រុះរើបោសសម្អាត" សំដៅដល់ចំណាយសរុបសម្រាប់រុះរើបោសសម្អាតនៅក្នុងតំបន់ចុះកិច្ចសន្យា ដែលបានយល់ព្រមដោយស្ថាប័ន តាមគម្រោងរុះរើបោសសម្អាតរបស់អ្នកជាប់ពន្ធ ស្របតាមកិច្ចព្រមព្រៀងប្រេងកាត ដូចដែលបានកែប្រែទៅតាមពេលវេលានីមួយៗ

ឋ. ពាក្យ "ផលិតកម្មពាណិជ្ជកម្ម" សំដៅដល់សកម្មភាពផលិតប្រេងកាតដែលអាចកើតឡើងនៅពេលដែលមធ្យោបាយផលិតកម្មចាប់ផ្តើមដំណើរការផលិតជាលើកដំបូង ឬលក់ ឬនៅពេលដឹកជញ្ជូនផលិតផលប្រេងកាតចេញពីតំបន់ចុះកិច្ចសន្យាដើម្បីលក់។

២- សម្រាប់គោលដៅនៃប្រតិបត្តិការធនធានរ៉ែ ៖

ក. ពាក្យ "ធនធានរ៉ែ" សំដៅដល់សារធាតុទាំងឡាយ ទោះជាក្នុងទម្រង់រឹង រាវ ឧស្ម័ន ដែលកកើតឡើងដោយធម្មជាតិតាមដំណើរវិវត្តភូគព្ភសាស្ត្រ ឬជាលទ្ធផលនៃការជីកយកពីក្នុងដី លើដី ក្នុងសមុទ្រ ក្រោមបាតសមុទ្រ មានជាអាទិ៍ ត្បូងថ្ម ត្បូងថ្ម រ៉ែអលោហៈ រ៉ែលោហៈ ទឹកខនិជ ថ្ម ក្រួស ខ្សាច់ និងដីឥដ្ឋ។ ពាក្យ "ធនធានរ៉ែ" មិនរាប់បញ្ចូលប្រេងកាតដូចមានចែងក្នុងវាក្យខណ្ឌក នៃកថាខណ្ឌ១ នៃមាត្រានេះទេ

ខ. ពាក្យ "អាជ្ញាបណ្ណ" សំដៅដល់លិខិតអនុញ្ញាតដែលផ្តល់សិទ្ធិឱ្យអ្នកជាប់ពន្ធ ដោយស្ថាប័នដើម្បីធ្វើប្រតិបត្តិការធនធានរ៉ែ

គ. ពាក្យ "កិច្ចព្រមព្រៀងធនធានរ៉ែ" សំដៅដល់កិច្ចព្រមព្រៀង ដែលតម្រូវឱ្យធ្វើបន្ថែមលើអាជ្ញាបណ្ណ ក្នុងករណីដែលអាជីវកម្មធនធានរ៉ែជាគម្រោងមានទ្រង់ទ្រាយធំ និងមានផលប្រយោជន៍ពិសេសដល់ប្រទេសជាតិ

ឃ. ពាក្យ "ប្រតិបត្តិការធនធានរ៉ែ" សំដៅដល់សកម្មភាពទាំងឡាយដែលបានអនុញ្ញាតក្រោមអាជ្ញាបណ្ណ ឬកិច្ចព្រមព្រៀងធនធានរ៉ែ។ ប្រតិបត្តិការធនធានរ៉ែត្រូវបានបែងចែកជាដំណាក់កាលបុរេសនា ដំណាក់កាលស្វែងរុករក ដំណាក់កាលអភិវឌ្ឍន៍ និងដំណាក់កាលផលិតកម្ម

ង. ពាក្យ "តំបន់ទទួលអាជ្ញាបណ្ណ" សំដៅដល់តំបន់ដែលត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការធនធានរ៉ែនិងជាកម្មវត្ថុនៃអាជ្ញាបណ្ណឬកិច្ចព្រមព្រៀងធនធានរ៉ែ រួមបញ្ចូលទាំងផ្នែកណាមួយនៃតំបន់ដែលត្រូវបានបោះបង់ចោល ដោយអនុលោមទៅតាមអាជ្ញាបណ្ណឬកិច្ចព្រមព្រៀងធនធានរ៉ែនោះ

ច. ពាក្យ "ផែនការស្តារបរិស្ថាន" សំដៅដល់ផែនការស្តារបរិស្ថានឡើងវិញរបស់អ្នកជាប់ពន្ធដែលបានយល់ព្រមដោយស្ថាប័ន ក្រោមអាជ្ញាបណ្ណឬកិច្ចព្រមព្រៀងធនធានរ៉ែ។ ការស្តារបរិស្ថាន រួមបញ្ចូលទាំងការលុបអណ្តូងរ៉ែ ការដាំដើមឈើឡើងវិញ ការសម្អាតនានាក្នុងតំបន់ទទួលអាជ្ញាបណ្ណ

ឆ. ពាក្យ "ចំណាយបុរេសនា" សំដៅដល់ចំណាយដែលទាក់ទិននឹងការស្វែងរុករកជំហានដំបូងនៅស្រទាប់ដីលើ ដោយប្រើប្រាស់ឧបករណ៍សាមញ្ញ ដែលមានការប៉ះពាល់បន្តិចបន្តួចដល់ផ្ទៃដី ដើម្បីកំណត់វត្តមានធនធានរ៉ែ

ជ. ពាក្យ "ចំណាយស្វែងរុករក" សំដៅដល់ចំណាយនានាទាក់ទិនទៅនឹង [illegible]សិក្សាស្រាវជ្រាវនិងធ្វើតេស្តសន្និស្សន៍រ៉ែ ដើម្បីកំណត់សក្តានុពល ទំហំ គុណភាព បរិមាណ [illegible]ទាំងលទ្ធភាព សេដ្ឋកិច្ចអាជីវកម្ម តាមរយៈការធ្វើបុរេសនា ការស្រាវជ្រាវភូគព្ភសាស្ត្រ

រូបភូគព្ភសាស្ត្រ និងគីមីភូគព្ភសាស្ត្រ ការជីកកកាយ ការខួង ការដឹកជញ្ជូន និងការធ្វើវិភាគដី ដីល្បាប់ ទឹក ថ្ម និងគំរូរ៉ែផ្សេងៗទៀត

ឈ. ពាក្យ "ចំណាយអភិវឌ្ឍន៍" សំដៅដល់ចំណាយនានាទាក់ទិនទៅនឹងការរៀបចំទីតាំងសម្រាប់ប្រតិបត្តិការធនធានរ៉ែ ជាអាទិ៍មាន ការសាងសង់ផ្លូវចេញចូល ផ្លូវដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធឬមធ្យោបាយផ្សេងៗ ក្នុងគោលបំណងជីកយក ចម្រាញ់ បន្សុទ្ធ ធ្វើប្រព្រឹត្តិកម្ម កែច្នៃ ផលិតកម្ម ស្តុកទុក ដឹកជញ្ជូន និងធ្វើពាណិជ្ជកម្មផលិតផលរ៉ែ

ញ. ពាក្យ "ប្រាក់បម្រុងសម្រាប់ចំណាយស្តារបរិស្ថាន" សំដៅដល់ប្រាក់បម្រុងដែលអនុញ្ញាតឱ្យកាត់កងជាមុន សម្រាប់ចំណាយស្តារបរិស្ថានឡើងវិញដែលនឹងត្រូវបានធ្វើឡើងស្របតាមផែនការស្តារបរិស្ថាន

ដ. ពាក្យ "ចំណាយសរុបដែលបានយល់ព្រមសម្រាប់ស្តារបរិស្ថាន" សំដៅដល់ចំណាយសរុបសម្រាប់ស្តារបរិស្ថានឡើងវិញនៅក្នុងតំបន់ទទួលអាជ្ញាបណ្ណ ដែលបានយល់ព្រមដោយស្ថាប័នតាមផែនការស្តារបរិស្ថានរបស់អ្នកជាប់ពន្ធ ស្របតាមអាជ្ញាបណ្ណឬកិច្ចព្រមព្រៀងធនធានរ៉ែ និងច្បាប់និងបទប្បញ្ញត្តិស្តីពីធនធានរ៉ែ

ឋ. ពាក្យ "ផលិតកម្មពាណិជ្ជកម្ម" សំដៅដល់សកម្មភាពប្រព្រឹត្តិកម្មធនធានរ៉ែដែលអាចកើតឡើងនៅពេលដែលមធ្យោបាយផលិតកម្មចាប់ផ្តើមដំណើរការផលិតជាលើកដំបូង ឬនៅពេលដែលការចាប់ផ្តើមដឹកជញ្ជូនចេញដើម្បីលក់ពីតំបន់ទទួលអាជ្ញាបណ្ណ។

៣- សម្រាប់គោលដៅនៃជំពូកនេះ ៖

ក. ពាក្យ "អ្នកជាប់ពន្ធ" សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលបានចុះកិច្ចព្រមព្រៀងប្រេងកាតជាមួយរាជរដ្ឋាភិបាលកម្ពុជា ឬដែលទទួលបានអាជ្ញាបណ្ណឬបានចុះកិច្ចព្រមព្រៀងធនធានរ៉ែឱ្យធ្វើប្រតិបត្តិការធនធានរ៉ែ រួមទាំងអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ

ខ. ពាក្យ "ស្ថាប័ន" សំដៅដល់ក្រសួងរ៉ែនិងថាមពល ឬស្ថាប័នរាជរដ្ឋាភិបាលដែលទទួលបន្ទុកគ្រប់គ្រងវិស័យប្រេងកាត ឬគ្រប់គ្រងវិស័យធនធានរ៉ែ។

## ផ្នែកទី២

## អត្រាពន្ធនិងប្រាក់ពន្ធត្រូវបង់

មាត្រា១៤៣ .-

១- អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាត និងអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការធនធានរ៉ែ ដូចមានចែងក្នុងមាត្រា១៤២ នៃច្បាប់នេះ ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រា

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៣០ ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធ។ សម្រាប់គោលដៅនៃច្បាប់នេះ ពាក្យ "ប្រាក់ចំណូលជាប់ពន្ធ" សំដៅដល់ ប្រាក់ចំណូលសុទ្ធដែលបានមកពីការយកចំណូលដុល សម្រេចបានពីប្រតិបត្តិការប្រេងកាតឬធនធានរ៉ែ ដកចំណាយនានាដែលអនុញ្ញាតដោយច្បាប់នេះ។

២- បន្ថែមលើអត្រាពន្ធដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ អ្នកជាប់ពន្ធត្រូវជាប់ពន្ធលើប្រាក់ចំណូលលើសកម្រិត តាមអត្រាកំណើនតាមថ្នាក់ដូចមានចែងក្នុងកថាខណ្ឌ៣ នៃមាត្រានេះ ដោយផ្អែកលើសមាមាត្រនៃប្រាក់ចំណូលលើសកម្រិត។ សមាមាត្រនៃប្រាក់ចំណូលលើសកម្រិតនៃឆ្នាំជាប់ពន្ធចរន្តណាមួយ គឺជាផលចែករវាងទឹកប្រាក់បូកបង្គរនៃចំណូល និងទឹកប្រាក់បូកបង្គរនៃចំណាយពីប្រតិបត្តិការប្រេងកាតឬធនធានរ៉ែ មកទល់នឹងឆ្នាំជាប់ពន្ធចរន្តនោះ។

៣- អត្រាពន្ធលើប្រាក់ចំណូលលើសកម្រិត មានដូចក្នុងតារាងខាងក្រោម ៖

| ថ្នាក់ | សមាមាត្រនៃប្រាក់ចំណូលលើសកម្រិត | អត្រាពន្ធលើប្រាក់ចំណូលលើសកម្រិត |
|---|---|---|
| ១ | ដល់ ១,៣ | ០ % |
| ២ | លើសពី ១,៣ ដល់ ១,៦ | ១០ % |
| ៣ | លើសពី ១,៦ ដល់ ២ | ២០ % |
| ៤ | លើសពី ២ ឡើងទៅ | ៣០ % |

វិធីគណនាសមាមាត្រនៃប្រាក់ចំណូលលើសកម្រិត ប្រាក់ចំណូលលើសកម្រិត ពន្ធលើប្រាក់ចំណូលលើសកម្រិត និងវិធាននិងនីតិវិធីនៃការគ្រប់គ្រងការប្រមូលពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤- អ្នកជាប់ពន្ធត្រូវបានលើកលែងពីការបង់ពន្ធអប្បបរមាដែលមានចែងក្នុងមាត្រា ២៤ថ្មី (ពីរ) នៃច្បាប់នេះ។

## ផ្នែកទី៣

## ការកាត់កង

មាត្រា១៤៤ .-

ចំណាយដែលត្រូវបានអនុញ្ញាតឱ្យកាត់កងដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធរបស់អ្នកជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំហិតដូចខាងក្រោម ៖

១- សម្រាប់ប្រតិបត្តិការប្រេងកាត ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ក. ចំណាយដែលទាក់ទិននឹងប្រតិបត្តិការប្រេងកាតនៅក្នុងតំបន់ចុះកិច្ចសន្យាណាមួយ សម្រាប់ឆ្នាំជាប់ពន្ធណាមួយ ត្រូវបានអនុញ្ញាតឱ្យកាត់កងតែពីប្រាក់ចំណូលដុលសរុបពីប្រតិបត្តិការប្រេងកាតក្នុងតំបន់ចុះកិច្ចសន្យានៃឆ្នាំជាប់ពន្ធនោះប៉ុណ្ណោះ

ខ. ប្រសិនបើនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ចំណាយសរុបដែលទាក់ទិននឹងប្រតិបត្តិការប្រេងកាតនៅក្នុងតំបន់ចុះកិច្ចសន្យា លើសពីចំណូលដុលសរុប ដែលនាំឱ្យមានលទ្ធផលខាតបង់ ការខាតបង់ត្រូវបានចាត់ទុកជាបន្ទុកសម្រាប់កាត់កងពីប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានក្នុងឆ្នាំជាប់ពន្ធបន្ទាប់។ ប្រសិនបើប្រាក់ចំណូលជាប់ពន្ធនោះមិនគ្រប់គ្រាន់សម្រាប់កាត់កងជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី១០។ ក្នុងករណីដែលមានការខាតបង់លើសពីមួយឆ្នាំ ការយោងការខាតបង់ត្រូវអនុវត្តតាមលំដាប់ឆ្នាំដែលការខាតបង់ទាំងឡាយបានកើតឡើង។

២- សម្រាប់ប្រតិបត្តិការធនធានរ៉ែ ៖

ក. ចំណាយដែលទាក់ទិននឹងប្រតិបត្តិការធនធានរ៉ែ នៅក្នុងតំបន់ទទួលអាជ្ញាបណ្ណណាមួយសម្រាប់ឆ្នាំជាប់ពន្ធណាមួយ ត្រូវបានអនុញ្ញាតឱ្យកាត់កងតែពីប្រាក់ចំណូលដុលសរុបពីប្រតិបត្តិការធនធានរ៉ែក្នុងតំបន់ទទួលអាជ្ញាបណ្ណនៃឆ្នាំជាប់ពន្ធនោះប៉ុណ្ណោះ

ខ. ប្រសិនបើនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ចំណាយសរុបដែលទាក់ទិននឹងប្រតិបត្តិការធនធានរ៉ែនៅក្នុងតំបន់ទទួលអាជ្ញាបណ្ណ លើសពីចំណូលដុលសរុប ដែលនាំឱ្យមានលទ្ធផលខាតបង់ ការខាតបង់ត្រូវបានចាត់ទុកជាបន្ទុកសម្រាប់កាត់កងពីប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានក្នុងឆ្នាំជាប់ពន្ធបន្ទាប់។ ប្រសិនបើប្រាក់ចំណូលជាប់ពន្ធនោះមិនគ្រប់គ្រាន់សម្រាប់កាត់កងជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី៥។ ក្នុងករណីដែលមានការខាតបង់លើសពីមួយឆ្នាំ ការយោងការខាតបង់ត្រូវអនុវត្តតាមលំដាប់ឆ្នាំដែលការខាតបង់ទាំងឡាយបានកើតឡើង។

៣- ការខាតបង់ដែលកើតមានឡើងក្នុងតំបន់ចុះកិច្ចសន្យាឬតំបន់ទទួលអាជ្ញាបណ្ណណាមួយ មិនអាចយោងយកទៅកាត់កងក្នុងតំបន់ចុះកិច្ចសន្យាឬតំបន់ទទួលអាជ្ញាបណ្ណដទៃទៀតឡើយ។

**មាត្រា១៤៥ .-**

អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យកាត់កងចំណាយការប្រាក់តាមវិធានសមាមាត្រ ៣ ធៀបនឹងដើមទុន ១។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា១៤៦ .-

ប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬចំណាយស្តារបរិស្ថាន ត្រូវបានកំណត់ដូចតទៅ ៖

១- ដោយមិនគិតពីបទប្បញ្ញត្តិនៃកថាខណ្ឌ២ និងកថាខណ្ឌ៤ នៃមាត្រា៦ថ្មី នៃច្បាប់នេះ ប្រសិនបើអ្នកជាប់ពន្ធមានគម្រោងរុះរើបោសសម្អាត ឬស្តារបរិស្ថានដែលបានយល់ព្រមដោយស្ថាប័ន អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យបង្កើតប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬស្តារបរិស្ថាន ដែលទាក់ទិននឹងប្រតិបត្តិការប្រេងកាតឬធនធានរ៉ែ។ ចំណាយសម្រាប់ប្រាក់បម្រុងទាំងនេះ ត្រូវបានអនុញ្ញាតឱ្យធ្វើសំវិធានធនសម្រាប់ចំណាយរុះរើបោសសម្អាត ឬស្តារបរិស្ថាន និងត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធ ដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធ។ ក្នុងករណីអ្នកជាប់ពន្ធគ្មានគម្រោងរុះរើបោសសម្អាត ឬស្តារបរិស្ថាន ដែលបានយល់ព្រមដោយស្ថាប័នទេ ការកាត់កងតាមមាត្រានេះមិនត្រូវបានអនុញ្ញាតឡើយ។

២- ប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬស្តារបរិស្ថាន ត្រូវបានគណនាដោយផ្អែកទៅតាមចំណាយសរុបដែលបានយល់ព្រមដោយស្ថាប័ន សម្រាប់រុះរើបោសសម្អាត ឬស្តារបរិស្ថាន។ ប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬស្តារបរិស្ថានក្នុងឆ្នាំនីមួយៗ និងឆ្នាំដែលប្រាក់បម្រុងត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមកាត់កង ត្រូវកំណត់តាមគម្រោងរុះរើបោសសម្អាត ឬស្តារបរិស្ថាន។

៣- ប្រសិនបើចំណាយសរុបជាក់ស្តែងនៃការរុះរើបោសសម្អាត ឬស្តារបរិស្ថាន មានចំនួនលើសពីចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬស្តារបរិស្ថាន ចំនួនលើសនោះត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ។

៤- ប្រសិនបើនៅចុងបញ្ចប់នៃការរុះរើបោសសម្អាត ឬស្តារបរិស្ថាន ចំណាយសរុបជាក់ស្តែងនៃការរុះរើបោសសម្អាត ឬស្តារបរិស្ថាន មានចំនួនតិចជាងចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬស្តារបរិស្ថាន ចំនួនលម្អៀងនោះត្រូវគិតបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធដែលការរុះរើបោសសម្អាត ឬស្តារបរិស្ថាននោះបានបញ្ចប់។

៥- នីតិវិធីគ្រប់គ្រងប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬស្តារបរិស្ថាន ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័ន។

មាត្រា១៤៧ .-

វិធីរំលស់ត្រូវបានកំណត់ ដូចខាងក្រោម ៖

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

១- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ តាមវិធីរំលស់ស្មើភាគតាមមាត្រា១៤៨ នៃច្បាប់នេះ។ អ្នកជាប់ពន្ធមិនត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍តាមមាត្រា១៥ នៃច្បាប់នេះទេ។

២- ចំពោះទ្រព្យរូបី និងទ្រព្យអរូបី ក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលបានទិញ ឬបានបង្កើតក្រោយពេលចាប់ផ្ដើមធ្វើផលិតកម្មពាណិជ្ជកម្ម ក្នុងតំបន់ចុះកិច្ចសន្យា ឬក្នុងតំបន់ទទួលអាជ្ញាបណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ទ្រព្យរូបីតាមវាក្យខណ្ឌក ដល់វាក្យខណ្ឌឃ នៃកថាខណ្ឌ១ នៃមាត្រា១៣ថ្មី នៃច្បាប់នេះ និងធ្វើរំលស់ទ្រព្យអរូបីតាមមាត្រា១៤ នៃច្បាប់នេះ។

មាត្រា១៤៨ .-

រំលស់ស្មើភាគសម្រាប់ប្រតិបត្តិការប្រេងកាតនិងប្រតិបត្តិការធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម ៖

១- សម្រាប់ប្រតិបត្តិការប្រេងកាត ៖

ក. អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា និងចំណាយស្វែងរុករកតាមវិធីរំលស់ស្មើកាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ ឬ ៥ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង

ខ. អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយអភិវឌ្ឍន៍ តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មរបស់មធ្យោបាយផលិតកម្មនីមួយៗក្រោមគម្រោងអភិវឌ្ឍន៍ ឬ ១០ឆ្នាំ សម្រាប់ប្រតិបត្តិការប្រេងកាត ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង

គ. ក្នុងករណីអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មរបស់មធ្យោបាយផលិតកម្មណាមួយក្រោមគម្រោងអភិវឌ្ឍន៍ត្រូវបានកែប្រែ អ្នកជាប់ពន្ធត្រូវធ្វើការកែតម្រូវការធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលនៅសល់តាមអាយុកាលរំពឹងទុកដែលកែប្រែថ្មី ដោយមិនត្រូវឱ្យលើសពីអាយុកាលរំលស់តាមវាក្យខណ្ឌក និងវាក្យខណ្ឌខ នៃកថាខណ្ឌនេះឡើយ។

២- សម្រាប់ប្រតិបត្តិការធនធានរ៉ែ ៖

ក. អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា និងចំណាយស្វែងរុករកតាមវិធីរំលស់ស្មើកាគ តាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ ឬ៥ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង

ខ. អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយអភិវឌ្ឍន៍ តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ ឬ៧ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង

គ. ក្នុងករណីអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ត្រូវបានកែប្រែ អ្នកជាប់ពន្ធត្រូវធ្វើការកែតម្រូវការធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលនៅសល់តាមអាយុកាលរំពឹងទុកដែលកែប្រែថ្មី ដោយមិនត្រូវឱ្យលើសពីអាយុកាលរំលស់តាមវាក្យខណ្ឌក និងវាក្យខណ្ឌខ នៃកថាខណ្ឌនេះឡើយ

ឃ. ក្នុងករណីអ្នកជាប់ពន្ធមានគម្រោងអភិវឌ្ឍន៍ដែលមានរយៈពេលតិចជាងមួយឆ្នាំ ចំណាយអភិវឌ្ឍន៍នេះអាចបញ្ចូលទៅធ្វើរំលស់ក្នុងចំណាយបុរេសនា និងចំណាយស្វែងរុករក។

មាត្រា១៤៩ .-

ពេលធ្វើរំលស់ត្រូវបានកំណត់ដូចខាងក្រោម ៖

១- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ ដែលបានកើតឡើងមុនពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូង នៅដំណាច់ឆ្នាំជាប់ពន្ធដែលអ្នកជាប់ពន្ធចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងក្នុងតំបន់ចុះកិច្ចសន្យាឬតំបន់ទទួលអាជ្ញាបណ្ណ។

២- ក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងក្នុងតំបន់ចុះកិច្ចសន្យាឬតំបន់ទទួលអាជ្ញាបណ្ណ ប្រសិនបើអ្នកជាប់ពន្ធធ្វើបុរេសនាឬស្វែងរុករក ឬសាងសង់បន្តនូវមធ្យោបាយផលិតកម្មដទៃទៀតក្រោមគម្រោងអភិវឌ្ឍន៍ក្នុងតំបន់ចុះកិច្ចសន្យាឬតំបន់ទទួលអាជ្ញាបណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ តាមពេលដូចខាងក្រោម ៖

ក. នៅដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ ចំពោះចំណាយបុរេសនា ឬចំណាយស្វែងរុករក ទៅតាមលំដាប់ឆ្នាំដែលចំណាយនោះបានកើតឡើង

ខ. នៅដំណាច់ឆ្នាំជាប់ពន្ធដែលមធ្យោបាយផលិតកម្មនីមួយៗត្រូវបានដាក់ឱ្យប្រើប្រាស់ ចំពោះចំណាយអភិវឌ្ឍន៍។

រំលស់ត្រូវធ្វើដាច់ដោយឡែកៗពីគ្នាសម្រាប់មធ្យោបាយផលិតកម្មនីមួយៗក្រោមគម្រោងអភិវឌ្ឍន៍ ស្របតាមមាត្រា១៤៨ នៃច្បាប់នេះ ហើយត្រូវបូកសរុបបញ្ចូលគ្នាសម្រាប់គោលដៅកំណត់ក្នុងឆ្នាំជាប់ពន្ធ។

៣- ចំពោះទ្រព្យរូបី និងទ្រព្យអរូបី ក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលបានទិញ ឬបានបង្កើតក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្ម ក្នុងតំបន់ចុះកិច្ចសន្យាឬតំបន់ទទួលអាជ្ញាបណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់នៅដំណាច់ឆ្នាំជាប់ពន្ធ ដែលទ្រព្យទាំងនោះត្រូវបានដាក់ឱ្យប្រើប្រាស់។

## ផ្នែកទី៤
## ការផ្ទេរអត្ថប្រយោជន៍

**មាត្រា១៥០ .-**

ក្នុងករណីមានការផ្ទេរមួយផ្នែកឬទាំងស្រុងនៃអត្ថប្រយោជន៍ដែលជាសិទ្ធិ ឬចំណែក ក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណ ឬកិច្ចព្រមព្រៀងធនធានរ៉ែ តាមរូបភាពលក់ទិញ ដោះដូរ ឬធ្វើអំណោយ អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ និងបុគ្គលជាអ្នកទទួលបន្ត ត្រូវអនុវត្តដូចខាងក្រោម ៖

១- អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរត្រូវកត់ត្រាចំណូលទទួលបានពីការផ្ទេរអត្ថប្រយោជន៍ ក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណឬកិច្ចព្រមព្រៀងធនធានរ៉ែ ជាចំណូលពីប្រតិបត្តិការ ប្រេងកាត ឬធនធានរ៉ែ ដែលជាកម្មវត្ថុនៃពន្ធលើប្រាក់ចំណូលស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពី សារពើពន្ធ។

២- បុគ្គលជាអ្នកទទួលបន្តត្រូវ ៖

ក. បន្តអនុវត្តកាតព្វកិច្ចសារពើពន្ធពីអ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ ចំពោះ អត្ថប្រយោជន៍ដែលជាសិទ្ធិ ឬចំណែកដែលបានទទួល

ខ. បន្តធ្វើរំលស់ទ្រព្យរូបី ទ្រព្យអរូបី ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ តាមវិធាននិងនីតិវិធី និងមូលដ្ឋានដែលអ្នកជាប់ពន្ធដែលជាអ្នកផ្ទេរបាន ធ្វើរំលស់កន្លងមក

គ. ក្នុងករណីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណ ឬកិច្ចព្រមព្រៀងធនធានរ៉ែមានតម្លៃលើសពីតម្លៃពិតគណនេយ្យ តម្លៃលម្អៀងនោះត្រូវបាន ចាត់ទុកជាមូលនិធិពាណិជ្ជកម្ម។ បុគ្គលជាអ្នកទទួលបន្តត្រូវធ្វើរំលស់មូលនិធិពាណិជ្ជកម្មនេះ តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មដែលនៅសល់ ឬ ១០ឆ្នាំ សម្រាប់ប្រតិបត្តិការប្រេងកាត និង ៧ឆ្នាំ សម្រាប់ប្រតិបត្តិការធនធានរ៉ែ ដោយជ្រើសរើសយក ជម្រើសណាមួយដែលតិចជាង

ឃ. ក្នុងករណីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណ ឬកិច្ចព្រមព្រៀងធនធានរ៉ែមានតម្លៃតិចជាងតម្លៃពិតគណនេយ្យ តម្លៃលម្អៀងនោះត្រូវបានចាត់ទុកជាចំណូល។ បុគ្គលជាអ្នកទទួលបន្តត្រូវកត់ត្រាជាចំណូលសម្រាប់ឆ្នាំបន្តបន្ទាប់ ដោយបែងចែកចំណូលទាំងនេះតាមសមាមាត្រនៃអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មដែលនៅសល់ ឬ ១០ឆ្នាំ សម្រាប់ប្រតិបត្តិការប្រេងកាត និង ៧ឆ្នាំ សម្រាប់ប្រតិបត្តិការធនធានរ៉ែ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

## ផ្នែកទី៥

## ភាតព្វកិច្ចអ្នកជាប់ពន្ធ

មាត្រា១៥១ .-

អ្នកជាប់ពន្ធអនិវាសនជនដែលចុះកិច្ចព្រមព្រៀងប្រេងកាតឬកិច្ចព្រមព្រៀងធនធានរ៉ែជាមួយរាជរដ្ឋាភិបាលកម្ពុជា ដូចមានចែងក្នុងមាត្រា១៤២ នៃច្បាប់នេះ ត្រូវបង្កើតជាក្រុមហ៊ុនក្នុងស្រុកមួយសម្រាប់តំបន់ចុះកិច្ចសន្យាមួយ ស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលយ៉ាងតិច១៥ថ្ងៃ មុនពេលចាប់ផ្តើមសកម្មភាពសេដ្ឋកិច្ច។

អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់ពន្ធអាករប្រចាំខែ ប្រចាំឆ្នាំ ជូនរដ្ឋបាលសារពើពន្ធ ទៅតាមការកំណត់នៃច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ។

ប្រតិបត្តិករដែលជាតំណាងអ្នកជាប់ពន្ធទាំងអស់ក្នុងតំបន់ចុះកិច្ចសន្យា ឬតំបន់ទទួលអាជ្ញាបណ្ណត្រូវផ្តល់របាយការណ៍ និងឯកសារនានានៃប្រតិបត្តិការអាជីវកម្មក្នុងតំបន់ចុះកិច្ចសន្យាឬតំបន់ទទួលអាជ្ញាបណ្ណ តាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ។

## ផ្នែកទី៦

## អន្តរប្បញ្ញត្តិ

មាត្រា១៥២ .-

ការផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធចំពោះកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណ ឬកិច្ចព្រមព្រៀងធនធានរ៉ែណាមួយដែលបានធ្វើឡើងមុនពេលចូលជាធរមាននៃបទប្បញ្ញត្តិនៃជំពូកនេះ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

មាត្រា១៥៣ ._

អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាត និងអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការធនធានរ៉ែ ដូចមានចែងក្នុងមាត្រា១៤២ នៃច្បាប់នេះ ត្រូវអនុវត្តបទប្បញ្ញត្តិក្នុងជំពូកនេះនិងបទប្បញ្ញត្តិដទៃទៀតស្តីពីពន្ធដារ។ ក្នុងករណីដែលមានភាពមិនស្របគ្នា បទប្បញ្ញត្តិនៃជំពូកនេះមានឧត្តមានុភាពលើបទប្បញ្ញត្តិដទៃទៀតស្តីពីពន្ធដារ។>>

# ជំពូកទី ៤

## និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ ចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧

**មាត្រា១២ ._**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ត្រូវបានយល់ព្រមជាគោលការណ៍ផ្តល់ឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ទឹកប្រាក់ចំនួន៣៧១ ៣៩៧ ០០០ ០០០រៀល(បីរយចិតសិបមួយប៊ីលានបីរយកៅសិបប្រាំពីរលានរៀលគត់) ដែលត្រូវបានបែងចែកដូចតទៅ៖

១- ផ្តល់ជូនធនាគារអភិវឌ្ឍន៍ជនបទ សម្រាប់ការសាងសង់ឃ្លាំង និងឡសម្ងួត ទឹកប្រាក់ចំនួន១២០ ៧៨០ ០០០ ០០០រៀល(មួយរយម្ភៃប៊ីលានប្រាំពីររយប៉ែតសិបលានរៀលគត់)។

២- ផ្តល់ជូនធនាគារអភិវឌ្ឍន៍ជនបទ សម្រាប់ជំរុញស្ថិរភាពភាវូបនីយកម្មថ្លៃស្រូវ និងជំរុញការទិញស្រូវក្នុងស្រុក ទឹកប្រាក់ចំនួន៩៣ ៧៧១ ០០០ ០០០រៀល(កៅសិបបីប៊ីលានប្រាំពីររយចិតសិបមួយលានរៀលគត់)។

៣- ទូទាត់ការបង្វិលសងអាករលើតម្លៃបន្ថែមរបស់ក្រុមហ៊ុន ស្ថានទូត អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ទឹកប្រាក់ចំនួន ១៥០ ០០០ ០០០ ០០០រៀល(មួយរយហាសិបប៊ីលានរៀលគត់)។

៤- ទូទាត់ចំណាយរៀបចំមហាសន្និបាតតំបន់អាស៊ីលើកទី ៩ (APA-9) ទឹកប្រាក់ចំនួន៦ ៨៤៦ ០០០ ០០០រៀល(ប្រាំមួយប៊ីលានប្រាំបីរយសែសិបប្រាំមួយលានរៀលគត់)។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៥

## ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា១៣ .-**

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា៨៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ និងបទប្បញ្ញត្តិនៃមាត្រា៣៥ និងមាត្រា៥៤ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ចំណូល-ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ សរុបចំនួន១ ៦៨៤ ៦៧៤លានរៀល ត្រូវបានកំណត់ដូចខាងក្រោមនេះ ៖

### ក.ថវិការបស់រដ្ឋបាលរាជធានី ខេត្ត

- ចំណូលថវិកាសរុប...............................១ ០៩០ ២៣៣លានរៀល
  - +ចំណូលចរន្តសរុប.....................................៩៤១ ៤១៩លានរៀល
    - -ចំណូលសារពើពន្ធ............................ ៩១០ ៤៤៣លានរៀល
    - -ចំណូលមិនមែនសារពើពន្ធ.....................៣០ ៩៧៦លានរៀល
  - +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ..................១៤៨ ៨១៤លានរៀល
    - -ឧបត្ថម្ភរាជធានី ខេត្ត.......................... ១៤០ ៨១៤លានរៀល
    - -ឧបត្ថម្ភសេវាអនាម័យបរិស្ថាន.................. ៨ ០០០លានរៀល។
- ចំណាយថវិកាសរុប............................... ១ ០៩០ ២៣៣លានរៀល
  - +ចំណាយចរន្ត........................................ ៧៤៤ ៧២៨លានរៀល
  - +ចំណាយមូលធន...................................... ២១៩ ៥០៥លានរៀល
  - +អតិរេករាជធានី ខេត្ត................................១២៦ ០០០លានរៀល។

ចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត តាមមាតិកាថវិកា ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ក២**" និងឥណទានចំណាយបែងចែកទៅតាមរដ្ឋបាលរាជធានី ខេត្ត នីមួយៗនិងទៅតាមប្រភេទចំណាយ ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ខ២**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**ខ.ថវិការបស់រដ្ឋបាលក្រុង ស្រុក**

- ចំណូលថវិកាសរុប....................................... ១៦០ ៤០០លានរៀល
  - +ចំណូលចរន្តសរុប.......................................... ៥ ៣៨៥លានរៀល
    - -ចំណូលមិនមែនសារពើពន្ធ........................ ៥ ៣៨៥លានរៀល
  - +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ................ ១៥៥ ០១៥លានរៀល។
- ចំណាយថវិកាសរុប....................................... ១៦០ ៤០០លានរៀល
  - +ចំណាយចរន្ត...........................................១៦០ ៣៥៣លានរៀល
  - +ចំណាយមូលធន................................................ ៤៧លានរៀល។

**គ.ថវិការបស់រដ្ឋបាលឃុំ សង្កាត់**

- ចំណូលថវិកាសរុប....................................... ៤៣៤ ០៤១លានរៀល
  - +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិសរុប............ ៤៣៤ ០៤១លានរៀល
    - -ចំណូលសង្កាត់ចំណុះរាជធានី................ ៣០ ៧៥២លានរៀល
    - -ចំណូលសង្កាត់ចំណុះក្រុង...............៣៣ ៩៩៧,៤៧លានរៀល
    - -ចំណូលឃុំ...............................៣៦៩ ២៩១,៥៣លានរៀល។
- ចំណាយថវិកាសរុប....................................៤៣៤ ០៤១លានរៀល
  - +ចំណាយសរុប........................................... ៤៣៤ ០៤១លានរៀល
    - -ចំណាយសង្កាត់ចំណុះរាជធានី...............៣០ ៧៥២លានរៀល
    - -ចំណាយសង្កាត់ចំណុះក្រុង.............៣៣ ៩៩៧,៤៧លានរៀល
    - -ចំណាយឃុំ.............................៣៦៩ ២៩១,៥៣លានរៀល។

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់នីមួយៗ ក៏ដូចជាការបែងចែកឥណទាននៅផ្ទៃក្នុងថវិកាជាជំពូក គណនី និងអនុគណនី ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ។

# ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ពុធ ៣រោច ខែ មិគសិរ ឆ្នាំរកា ព.ស.២៥៦១

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៦ ខែ ធ្នូ គ.ស.២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម/១២១៧/០១៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**អូន ព័ន្ធមុនីរ័ត្ន**

លេខ:១១៧៤ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃអង្គារ០៩រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ,ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**